ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខៈ ១៤០៥ គ.ជ.ប

# បទបញ្ជាកម្មវិធីតុមូល

អនុលោមតាមច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ជំពូកទី៦ ស្តីពីការឃោសនាបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សម្រេចចេញបទបញ្ជាកម្មវិធីតុមូល សម្រាប់គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះផ្លូវការនៅ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ ដូចខាងក្រោមៈ

១. កម្មវិធីតុមូលមានប្រធានបទចំនួន ១ ដែលមាន ៥ សំណួរ ហើយក្នុងមួយសំណួរតំណាងគណបក្សមានរយៈពេលឆ្លើយ ៧នាទី។

២. តំណាងគណបក្សនយោបាយដែលចូលរួមក្នុងកម្មវិធីនេះ ត្រូវគោរពច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត។

៣. ការមិនមកចូលរួម ឬការមកមិនទាន់ពេលកំណត់ត្រូវបានចាត់ទុកថា សាមីគណបក្សនយោបាយ ឬតំណាងបោះបង់សិទ្ធិចូលរួមរបស់ខ្លួន។

៤. មិនអនុញ្ញាតឱ្យប្រើប្រាស់គ្រឿងសម្គាល់ ឬពាក់ស្លាកសញ្ញាណាមួយក្រៅពីសញ្ញាសម្គាល់របស់គណបក្សខ្លួន។

៥. មិនត្រូវយកវេទិកានេះប្រើប្រាស់ខុសពីបទបញ្ជាកម្មវិធីតុមូល។

៦. មិនត្រូវប្រើភាសាជៀមជាម អសីលធម៌ ហិង្សា បំភិតបំភ័យ គំរាមកំហែង ញុះញង់ បំបាក់ទឹកចិត្តទៅលើបុគ្គល ឬគណបក្សដទៃឡើយ។

៧. មិនត្រូវឃោសនាដោយប្រើប្រាស់ព្រះឆាយាល័ក្ខណ៍ ព្រះរាជឧទ្ធារ ព្រះរាជសារស្នាព្រះហស្ត និងព្រះនាមរបស់ព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រី ព្រះវររាជមាតា និងរូបសញ្ញា គ.ជ.ប ឡើយ។



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីម៉ែល : info@nec.gov.kh

៨. សំឡេងជូនដំណឹង៖

- កណ្ដឹងលើកទី១ ជាសញ្ញាប្រាប់ថា នៅសល់ពេល ២ (ពីរ) នាទី
- កណ្ដឹងលើកទី២ ជាសញ្ញាប្រាប់ថា អស់ពេលហើយ។

៩. ការរំលោភលើចំណុចណាមួយខាងលើ គណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយមានសិទ្ធិ៖

- បញ្ឈប់ការបកស្រាយប្រធានបទភ្លាមៗ
- តម្រូវឱ្យចេញពីវេទិកាក្នុងករណីធ្ងន់ធ្ងរ។

ថ្ងៃពុធ ១៤រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**